លេខ ៤០ ចេញផ្សាយថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៤

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែកញ្ញា ឆ្នាំ២០២៤

TRUST REGULATOR

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## មាតិកា


- ពិធីចុះអនុស្សរណៈរវាង ន.ប.ធ. ក្រុមហ៊ុន ប៉ូម៉ា មេឌា ឯ.ក ទំព័រទី១
- វេទិកាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទាននៃគម្រោង ACSEP កម្រិតសហគមន៍" ទំព័រទី២
- កិច្ចប្រជុំស្តីពី "បូកសរុបលទ្ធផលនៃការចរចាសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥" ទំព័រទី២
- កិច្ចប្រជុំគណៈកម្មការវាយតម្លៃកម្មវិធីប្រកួតសរសេរអត្ថបទក្នុងវិស័យបរធនបាលកិច្ច ទំព័រទី៣
- កិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី២ ឆ្នាំ២០២៤ ទំព័រទី៣
- កិច្ចប្រជុំស្តីពី "ការពិនិត្យវឌ្ឍនភាពការងារពាក់កណ្តាលអាណត្តិគម្រោង ACSEP" ទំព័រទី៣
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ឆ្នាំ២០២៣-២០២៨" ទំព័រទី៤
- កិច្ចប្រជុំស្តីពី គណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទំព័រទី៤
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី "បរធនបាលកិច្ច៖ យន្តការប្រកបដោយពលានុភាព និងទំនុកចិត្តខ្ពស់សម្រាប់វិនិយោគិនបរទេស" ទំព័រទី៤
- កិច្ចប្រជុំដំបូងរបស់ក្រុមការងារលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ (ក.ប.ហ.) ទំព័រទី៥
- សិក្ខាសាលាត្រៀមលក្ខណៈសម្រាប់ការរៀបចំថវិកា និងទិសដៅការងារឆ្នាំ២០២៥ របស់ អ.ស.ហ. ទំព័រទី៥
- ការចុះត្រួតពិនិត្យ និងវាយតម្លៃការងារពាក់កណ្តាលអាណត្តិគម្រោង ACSEP នៅខេត្តកំពង់ធំ ព្រះវិហារ និងឧត្តរមានជ័យ ទំព័រទី៦
- កម្មវិធីបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីស្តីពី "ការចែករំលែកបទពិសោធអំពីយន្តការបរធនបាលកិច្ចឥណទានកាបូននៅកម្ពុជា" ទំព័រទី៦
- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករមូលបត្រកម្ពុជា និងគណៈកម្មាធិការរដ្ឋាភិបាលឱ្យជីថល ទំព័រទី៧
- ការចុះត្រួតពិនិត្យមើលវឌ្ឍនភាពនៃការសាងសង់អគារសាលាបឋមសិក្សាប្រឡាយទ្រៀក នៅភូមិប្រឡាយទ្រៀក ឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ ទំព័រទី៧
- កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" ទំព័រទី៨
- កិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស TWG ទំព័រទី៨
- កិច្ចប្រជុំបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ទំព័រទី៩
- កិច្ចប្រជុំពិភាក្សាអំពីបច្ចុប្បន្នភាពនៃទីផ្សារបរធនបាលកិច្ច ការរៀបចំនិងប្រព្រឹត្តិទៅរបស់បរធនបាលកិច្ច ទំព័រទី៩


## ពិធីចុះអនុស្សរណៈរវាង ន.ប.ធ. ក្រុមហ៊ុន ប៉ូម៉ា មេឌា ឯ.ក

ថ្ងៃចន្ទ ១៤ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)** និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងក្រុមហ៊ុន ប៉ូម៉ា មេឌា ឯ.ក បានចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "ការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **លោក សុក ចន្លា** អនុប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ប៉ូម៉ា មេឌា ឯ.ក នៅទីស្តីការ **អ.ស.ហ.**។ ការចុះអនុស្សរណៈនៃការយោគយល់គ្នានេះ មានគោលបំណងដើម្បីបង្កើតនូវក្របខណ្ឌកិច្ចសហប្រតិបត្តិការសំដៅផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ច តាមរយៈយន្តការផ្សព្វផ្សាយបែបពាណិជ្ជកម្មនៅតាមទីសាធារណៈ។ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នានេះ មានការអញ្ជើញចូលរួមពីតំណាងជាន់ខ្ពស់នៃនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ថ្នាក់ដឹកនាំនៃក្រុមហ៊ុន ប៉ូម៉ា មេឌា ឯ.ក តំណាងក្រុមហ៊ុនបរធនបាល និងបុគ្គលពាក់ព័ន្ធផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia ☎ (855) 23 237 888




**រូបភាព៖** ការចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី "ការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីវិស័យបរធនបាលកិច្ច" ។

## វេទិកាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទាននៃគម្រោង ACSEP កម្រិតសហគមន៍"

នាព្រឹកថ្ងៃពុធ ២ កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែប្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំវេទិកាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទាននៃគម្រោង ACSEP កម្រិតសហគមន៍" នៅខេត្តកំពង់ធំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជានាយកគម្រោង និង **ឯកឧត្តម នួន ផារ័ត្ន** អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ។

គោលបំណងធ្វើការផ្សព្វផ្សាយបន្ថែមដល់សមាជិកសហគមន៍ រួមមាន សហគមន៍សាលាវិស័យ សហគមន៍ព្រៃនរូកចម្រើន សហគមន៍យាសាមគ្គី សហគមន៍ភ្នំសន្ទុក និងសហគមន៍បល្ល័ងមានជ័យ អាជ្ញាធរមូលដ្ឋាន និងភ្នាក់ងារឥណទានគម្រោង ACSEP តាមខេត្ត ស្រុក និងឃុំគោលដៅ, ផ្តល់ព័ត៌មានអំពីការផ្តល់ឥណទាន តាមរយៈគម្រោង ACSEP ដល់សមាជិកសហគមន៍កសិកម្មក្នុងក្រុមគោលដៅ និងបង្ហាញអំពីនីតិវិធីដែលអាចទទួលបានឥណទានដល់សមាជិកសហគមន៍កសិកម្ម ដែលមានបំណងស្វែងរកហិរញ្ញប្បទានបន្ថែមដើម្បីគាំទ្រផែនការអាជីវកម្មក្នុងវិស័យកសិកម្ម។ កម្មវិធីនេះចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងធនាគារស្ថាបនា។



**រូបភាព៖** វេទិកាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទាននៃគម្រោង ACSEP កម្រិតសហគមន៍"។

## កិច្ចប្រជុំស្តីពី "បូកសរុបលទ្ធផលនៃការចរចាសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥"

នាព្រឹកថ្ងៃព្រហស្បតិ៍ ៣កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែកញ្ញា គ.ស ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច **(ន.ប.ធ.)** អមដោយ **ឯកឧត្តម ណើ សកល** អគ្គនាយករងនៃ **ន.ប.ធ., លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និងសហការី បានចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលនៃការចរចាសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **(កសហវ)** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាពក្រោមឱវាទ **កសហវ** តាមប្រព័ន្ធអនឡាញ Zoom។



**រូបភាព៖** ចូលរួមកិច្ចប្រជុំស្តីពី "បូកសរុបលទ្ធផលនៃការចរចាសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥"

## កិច្ចប្រជុំគណៈកម្មការវាយតម្លៃកម្មវិធីប្រកួតសរសេរអត្ថបទក្នុងវិស័យបរធនបាលកិច្ច

នាព្រឹកថ្ងៃអង្គារ ៨កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១០ ខែកញ្ញា គ.ស. ២០២៤ **ឯកឧត្តម ឈី សាភល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាអនុប្រធានគណៈកម្មការវាយតម្លៃកម្មវិធីប្រកួតសរសេរអត្ថបទក្នុងវិស័យបរធន-បាលកិច្ច បានដឹកនាំកិច្ចប្រជុំគណៈកម្មការវាយតម្លៃកម្មវិធីប្រកួតសរសេរអត្ថបទក្នុងវិស័យបរធនបាលកិច្ច ដើម្បីពិនិត្យ និងវាយតម្លៃលើសំណេរអត្ថបទរបស់បេក្ខជន ក្នុងកម្មវិធីប្រកួតសរសេរអត្ថបទក្នុងវិស័យបរធនបាលកិច្ច ក្រោមប្រធានបទ "បរធនបាលកិច្ច៖ លើសពីថ្នាលបង្កើនទំនុកចិត្តក្នុងធុរកិច្ច"។ កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីលោក/លោកស្រី ដែលជាសមាជិក/សមាជិកាគណៈកម្មការវាយតម្លៃកម្មវិធីប្រកួតសរសេរអត្ថបទក្នុងវិស័យបរធនបាលកិច្ចទាំងអស់។



**រូបភាព៖** កិច្ចប្រជុំស្តីពី "ការដឹកនាំគណៈកម្មការវាយតម្លៃកម្មវិធីប្រកួតសរសេរអត្ថបទក្នុងវិស័យបរធនបាលកិច្ច ដើម្បីពិនិត្យ និងវាយតម្លៃលើសំណេរអត្ថបទរបស់បេក្ខជន ក្នុងកម្មវិធីប្រកួតសរសេរអត្ថបទក្នុងវិស័យបរធនបាលកិច្ច"។

## កិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី២ ឆ្នាំ២០២៤

នាព្រឹកថ្ងៃពុធ ៩កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែកញ្ញា គ.ស.២០២៤ **ឯកឧត្តម ឈី សាភល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី២ ឆ្នាំ២០២៤ ក្រោម-អធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ និងថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។



**រូបភាព៖** កិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យនិងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី២ឆ្នាំ២០២៤។

## កិច្ចប្រជុំស្តីពី "ការពិនិត្យវឌ្ឍនភាពការងារពាក់កណ្តាលអាណត្តិគម្រោង ACSEP"

នារសៀលថ្ងៃពុធ ៩កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៤ នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និយ័តករបរធនបាលកិច្ច (**ន.ប.ធ**) ដែលជាអង្គភាពអនុវត្តគម្រោង ACSEP សមាសភាគទី១ បានរៀបចំកិច្ចប្រជុំជាមួយប្រតិភូធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ស្តីពី "ការពិនិត្យវឌ្ឍនភាពការងារពាក់កណ្តាលអាណត្តិគម្រោង ACSEP" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងជានាយកគម្រោង ACSEP សមាសភាគទី១ ដោយមានការចូលរួមពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP សមាសភាគទី១, **លោកស្រី Hyunyoung Song** ប្រធានក្រុមបេសកកម្មធនាគារអភិវឌ្ឍន៍អាស៊ី (ADB), លោកបណ្ឌិត Takeshi Ueda និងក្រុមការងារ, សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, **លោក Wong Keet Loong** នាយកប្រតិបត្តិ សាជីវកម្មធានាឥណទានកម្ពុជា និងសហការី,សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងមកពីអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុលនៃ **ក.ស.ហ.វ.**, តំណាងអង្គភាពគ្រប់គ្រងគម្រោងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ កិច្ចប្រជុំជាមួយប្រតិភូធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ស្ដីពី "ការពិនិត្យវឌ្ឍនភាពការងារពាក់កណ្ដាលអាណត្តិគម្រោង ACSEP"។

## សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ឆ្នាំ២០២៣-២០២៨"

នាព្រឹកថ្ងៃព្រហស្បតិ៍ ១០កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែកញ្ញា គ.ស.២០២៤ **ឯកឧត្តម ណឺ សារកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ ន.ប.ធ. អមដោយសហការី បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្ដីពីគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ឆ្នាំ២០២៣-២០២៨ ក្រោមប្រធានបទ "រួមគ្នាកសាងកម្ពុជាមួយដែលគ្មានអេដស៍" នៅទីស្ដីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ កែវ ចរិយា** រដ្ឋលេខាធិការ **កសហវ** និងជាប្រធានប្រចាំការគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាពក្រោមឱវាទ **កសហវ** នៅទីស្ដីការ **កសហវ**។



រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ឆ្នាំ២០២៣-២០២៨"។

## កិច្ចប្រជុំស្ដីពី គណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

នាព្រឹកថ្ងៃចន្ទ ១៤កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៦ ខែកញ្ញា គ.ស. ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) អមដោយ **ឯកឧត្តម ណឺ សារកល** អគ្គនាយករងនៃ ន.ប.ធ., **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការីបានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី២ ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំស្ដីពីគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "បរធនបាលកិច្ច៖ យន្តការប្រកបដោយពលានុភាព និងទំនុកចិត្តខ្ពស់សម្រាប់វិនិយោគិនបរទេស"

នាព្រឹកថ្ងៃអង្គារ ១៥កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច សហការជាមួយក្រុមហ៊ុន អេស អ៊ិម គ្លូបិល ត្រាស់ & អ៊ិនវេសមេន មេណេជឺមេន ឯ.ក បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "បរធនបាលកិច្ច៖ យន្តការប្រកបដោយពលានុភាព និងទំនុកចិត្តខ្ពស់សម្រាប់វិនិយោគិនបរទេស" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច, **លោក យ៉ាង សុងមូ** នាយកប្រតិបត្តិ នៃក្រុមហ៊ុន អេស អ៊ិម គ្លូបិល ត្រាស់ & អ៊ិនវេសមេន មេណេជឺមេន ឯ.ក, **លោក ផុង ម្យុងស្សូ** ប្រធានសមាគមកូរ៉េនៅកម្ពុជា



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

និង **លោក លី ហ្យុងស៊ីក** ប្រធាននៃសមាគមសាសនទូតកូរ៉េនៅសណ្ឋាគារ ភ្នំពេញ។ គោលបំណងដើម្បីបញ្ជ្រាបការយល់ដឹងឱ្យបានកាន់តែទូលំទូលាយពីកាលានុវត្តភាព និងគុណប្រយោជន៍នៃយន្តការបរធនបាលកិច្ច ព្រមទាំងជំរុញការចូលរួមក្នុងវិស័យបរធនបាលកិច្ចរបស់ថ្នាក់ដឹកនាំ និងបុគ្គលិក នៃក្រុមហ៊ុន អេស អ៊ុម គ្លូបិល ត្រាស់ & អ៊ិនវេសមេន មេណេជឺមេន ឯ.ក និងសហគមន៍កូរ៉េនៅកម្ពុជា ដែលជាវិនិយោគិន និងធុរជនសក្តានុពលនៅកម្ពុជា ដើម្បីអាចទាញយកផលប្រយោជន៍ជាអតិបរមាពីយន្តការបរធនបាលកិច្ចសម្រាប់គម្រោងវិនិយោគនិសកម្មភាពធុរកិច្ចរបស់ខ្លួន។



រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី "បរធនបាលកិច្ច៖ យន្តការប្រកបដោយពលានុភាព និងទំនុកចិត្តខ្ពស់សម្រាប់វិនិយោគិនបរទេស"។

## កិច្ចប្រជុំដំបូងរបស់ក្រុមការងារលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ (ក.ប.ហ.)

នៅរសៀលថ្ងៃអង្គារ ១៥កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែកញ្ញា គ.ស.២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាអនុប្រធានក្រុមការងារលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិន-មែនធនាគារ (**ក.ប.ហ.**) និងក្រុមការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ បានអញ្ជើញចូលរួមកិច្ចប្រជុំដំបូងរបស់ក្រុមការងារលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ (**ក.ប.ហ.**) និងកិច្ចប្រជុំលើកទី២ របស់ក្រុមការងាររៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** និងជាប្រធាននៃក្រុមការងារទាំងពីរ។



រូបភាព៖ កិច្ចប្រជុំដំបូងរបស់ក្រុមការងារលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ (ក.ប.ហ.)។

## សិក្ខាសាលាត្រៀមលក្ខណៈសម្រាប់ការរៀបចំថវិកា និងទិសដៅការងារឆ្នាំ២០២៥ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នាព្រឹកថ្ងៃអង្គារ ១៥ កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែកញ្ញា គ.ស.២០២៤ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករធនបាលកិច្ច អមដោយ **លោក យុន វាសនា** និងសហការីបានអញ្ជើញចូលរួមសិក្ខាសាលាត្រៀមលក្ខណៈសម្រាប់ការរៀបចំថវិកា និងទិសដៅការងារឆ្នាំ២០២៥ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាតំណាងអង្គភាពក្រោមឱវាទ **អ.ស.ហ.** នៅមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។



រូបភាព៖ សិក្ខាសាលាត្រៀមលក្ខណៈសម្រាប់ការរៀបចំថវិកា និងទិសដៅការងារឆ្នាំ២០២៥ របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## ការចុះត្រួតពិនិត្យ និងវាយតម្លៃការងារពាក់កណ្ដាលអាណត្តិគម្រោង ACSEP នៅខេត្តកំពង់ធំ ព្រះវិហារ និងឧត្ដរមានជ័យ

ចាប់ពីថ្ងៃសៅរ៍ ១២កើត ដល់ថ្ងៃពុធ ១៥កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៤-១៧ ខែកញ្ញា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1, **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្ដុះបណ្ដាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 បានដឹកនាំក្រុមការងារចូលរួមអមប្រតិភូធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ចុះត្រួតពិនិត្យ និងវាយតម្លៃការងារពាក់កណ្ដាលអាណត្តិគម្រោង ACSEP នៅខេត្តកំពង់ធំ ព្រះវិហារ និងឧត្តរមានជ័យ នៅតាមបណ្ដាសហគមន៍ សហគ្រាសកសិធុរកិច្ចមួយចំនួន និងការដ្ឋានសាងសង់ផ្លូវដូចជា៖ ១). សហគមន៍កសិកម្មចម្រើនជីវភាព សហគមន៍កសិកម្មទំនើបប្រាសាទសំបូររុងរឿង និងសហគមន៍កសិកម្មកែលម្អជីវភាពកសិករ (ខេត្តកំពង់ធំ), សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ (ខេត្តព្រះវិហារ), និងសហគមន៍កសិកម្មភូមិខ្ញុំ (ខេត្តឧត្តរមានជ័យ) ២). ចម្ការអភិរក្ស និងផ្ទះសំណាញ់ និងសហគ្រាសកសិធុរកិច្ចផ្សេងៗ និង ៣). ការដ្ឋានសាងសង់ផ្លូវថ្នល់ចាប់ពីភូមិសាលាវិស័យ ដល់ភូមិអូរគ្រូ (ខេត្តកំពង់ធំ) និងចាប់ពីភូមិសង្គមថ្មី ដល់ភូមិតាសែង (ខេត្តព្រះវិហារ)។ បេសកកម្មដ៏សំខាន់នេះ ដែលមានការចូលរួមពីសំណាក់ **លោកស្រី Hyunyoung Song** ប្រធានក្រុមបេសកកម្មនៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងក្រុមការងារ តំណាងធនាគារ ADB, **លោកបណ្ឌិត សរ ចិត្រា** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជានាយកគម្រោង ACSEP-PIU2 និងក្រុមការងារ, មន្ត្រី និងទីប្រឹក្សារបស់គម្រោង ACSEP-PIU1 និង ACSEP-PIU3, ទីភ្នាក់ងារបារាំងសំរាប់អភិវឌ្ឍន៍ (AFD), ប្រធានមន្ទីរកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ, និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ (ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា)។



រូបភាព៖ ការចុះត្រួតពិនិត្យ និងវាយតម្លៃការងារពាក់កណ្ដាលអាណត្តិគម្រោង ACSEP នៅខេត្តកំពង់ធំ ព្រះវិហារ និងឧត្តរមានជ័យ។

## កម្មវិធីបណ្ដុះបណ្ដាលកសាងសមត្ថភាពមន្ត្រីស្ដីពី "ការចែករំលែកបទពិសោធអំពីយន្តការបរធនបាលកិច្ចឥណទានកាបូននៅកម្ពុជា"

នាព្រឹកថ្ងៃពុធ ១រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកម្មវិធីបណ្ដុះបណ្ដាលកសាងសមត្ថភាពមន្ត្រីស្ដីពី "ការចែករំលែកបទពិសោធអំពីយន្តការបរធនបាលកិច្ចឥណទានកាបូននៅកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច នៅទីស្ដីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ កម្មវិធីបណ្ដុះបណ្ដាលនេះត្រូវបានរៀបចំឡើងក្នុងគោលដៅលើកកម្ពស់ការយល់ដឹង និងពង្រឹងសមត្ថភាពផ្ទៃក្នុងដល់មន្ត្រីនៃ **ន.ប.ធ.**។

កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, វាគ្មិនកិត្តិយស **លោក អ៊ឹង សុភាល័ក្ខ** ប្រធានក្រុមហ៊ុន មេធាវី អនន្ត និង**លោក CHEN, HAN-EN** នាយក-ប្រតិបត្តិ នៃក្រុមហ៊ុន ស្រ្តងហូល ត្រាសធី ឯ.ក, តំណាងពីអគ្គ-លេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងនិយ័តករ/អង្គភាពក្រោមឱវាទនៃ **អ.ស.ហ.**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ រៀបចំកម្មវិធីបណ្តុះបណ្តាលកសាងសមត្ថភាពមន្ត្រីស្តីពី"ការចែករំលែកបទពិសោធអំពីយន្តការបរធនបាលកិច្ចឥណទានកាបូននៅកម្ពុជា"។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករមូលបត្រកម្ពុជា និងគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល

នាព្រឹកថ្ងៃសុក្រ ៣រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពី "កិច្ចសហប្រតិបត្តិការដាក់ឱ្យប្រើថ្នាលផ្ទៀង-ផ្ទាត់ឯកសារ verify.gov.kh និងការបណ្តុះបណ្តាលជំនាញឌីជីថលជូនមន្ត្រីនៃនិយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**)" រវាង **ន.ម.ក.** និងគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល និងសិក្ខាសាលាស្តីពី "ការប្រើថ្នាល និងសេវារដ្ឋាភិបាលឌីជីថលក្នុងវិស័យមូលបត្រ" នៅមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។



រូបភាព៖ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករមូលបត្រកម្ពុជា និងគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល។

## ការចុះត្រួតពិនិត្យមើលវឌ្ឍនភាពនៃការសាងសង់អគារសាលាបឋមសិក្សាប្រឡាយទ្រៀក នៅភូមិប្រឡាយទ្រៀក ឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ

នារសៀលថ្ងៃអាទិត្យ ៥រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែកញ្ញា គ.ស.២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃ **ន.ប.ធ.**, **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចុះត្រួតពិនិត្យមើលវឌ្ឍនភាពនៃការសាងសង់អគារសាលាបឋមសិក្សាប្រឡាយទ្រៀក នៅភូមិប្រឡាយទ្រៀក ឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ ដែលកសាងថ្មីឡើងក្រោមគំនិតផ្តួចផ្តើមរបស់និយ័តករបរធនបាលកិច្ចនិងមានការចូលរួមឧបត្ថម្ភគាំទ្រពីបរធនបាលកិច្ចហិរញ្ញវត្ថុ និងក្រុមបរធនបាល។



រូបភាព៖ ការចុះត្រួតពិនិត្យមើលវឌ្ឍនភាពនៃការសាងសង់អគារសាលាបឋមសិក្សាប្រឡាយទ្រៀក នៅភូមិប្រឡាយទ្រៀក ឃុំដំរីផុង ស្រុកឆ្លូង ខេត្តក្រចេះ។

## កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច"

នាព្រឹកថ្ងៃចន្ទ ៦រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានសហការជាមួយរដ្ឋបាលខេត្តក្រចេះ រៀបចំកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ ន.ប.ធ. និង **ឯកឧត្តម ទុយ ម៉ុនសេរីរ័ត្នមុនី** អភិបាលរងនៃគណៈអភិបាលខេត្តក្រចេះ នៅសាលមហោស្រពខេត្តក្រចេះ។ សិក្ខាសាលាផ្សព្វផ្សាយនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណង បញ្ជ្រាបការយល់ដឹងបន្ថែមឱ្យបានកាន់តែទូលំទូលាយដល់មន្ទីរ និងអង្គភាពចំណុះរដ្ឋបាលខេត្ត កងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទនៅខេត្តក្រចេះ គ្រប់ស្ថាប័នពាក់ព័ន្ធ និងសាធារណជន ថាតើអ្វីទៅជាបរធនបាលកិច្ច? បរធនបាលកិច្ចមានយន្តការ និងប្រតិបត្តិការដូចម្តេច? ធ្វើដូចម្តេចទើបការបង្កើត និងចុះបញ្ជីបរធនបាលកិច្ចមានភាពត្រឹមត្រូវ និងមានអនុលោមភាពតាមច្បាប់? សិក្ខាសាលានេះ **ឯកឧត្តម សុខ ដារ៉ា** បានគូសរំលេចផងដែរអំពីតួនាទី និងសារសំខាន់របស់យន្តការបរធនបាលកិច្ចក្នុងការបង្កើតទំនុកចិត្ត ក៏ដូចជាការទាក់ទាញការវិនិយោគបន្ថែម ជាពិសេសចូលរួមចំណែកក្នុងការជំរុញដំណើរការអភិវឌ្ឍន៍គម្រោងធុរកិច្ចនានាក្នុងខេត្តក្រចេះ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ គិតត្រឹមថ្ងៃនេះ ទីផ្សារបរធនបាលកិច្ចមានទំហំសរុបចំនួន ១.៦១០ លានដុល្លារអាមេរិក និងមានបរធនបាលកិច្ចចំនួន ១.០២៦ ករណី ដែលបានបង្កើតនិងចុះបញ្ជី ព្រមទាំងមានប្រតិបត្តិករបរធនបាលសរុបចំនួន ៣៤ ដែលក្នុងនោះ រួមមានក្រុមហ៊ុនបរធនបាលចំនួន ១៣ និងធនាគារពាណិជ្ជដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកចំនួន ២១ ធនាគារ, បរធនបាលរូបវន្តបុគ្គលចំនួន ៦៥ រូប ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.** និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃចំនួន ១៦ និងក្រុមហ៊ុនផ្តល់សេវាសវនកម្មចំនួន ១៥ ដែលទទួលបានការទទួលស្គាល់ពី **ន.ប.ធ.**។ សិក្ខាសាលាផ្សព្វផ្សាយនេះ ក៏មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងតំណាងមកពីមន្ទីរអង្គភាពចំណុះរដ្ឋបាលខេត្ត កងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទនៅខេត្តក្រចេះ, សមាជិក-សមាជិកានៃសភាពាណិជ្ជកម្ម, និងសមាគមធុរកិច្ចពាក់ព័ន្ធ ព្រមទាំងថ្នាក់ដឹកនាំ និងតំណាងមកពីក្រុមហ៊ុនបរធនបាល, ធនាគារពាណិជ្ជដែលជាប្រតិបត្តិការបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក និងបរធនបាលរូបវន្តបុគ្គលឯករាជ្យ ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.**។



**រូបភាព៖** កម្មវិធីសិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច"។

## កិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស TWG

នាព្រឹកថ្ងៃពុធ ៨រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា គ.ស.២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃ **ន.ប.ធ.**, **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស TWG ដើម្បីពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី២ ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួងស្ថាប័ន តំណាងដៃគូអភិវឌ្ឍន៍ តំណាងអង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារបច្ចេកទេស TWG។

## កិច្ចប្រជុំបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុ មិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃព្រហស្បតិ៍ ៩រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែកញ្ញា គ.ស. ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **ឯកឧត្តម ណី សាកល** អគ្គនាយករងនៃ **ន.ប.ធ.** បានដឹកនាំសហការីចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** អនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។



រូបភាព៖ កិច្ចប្រជុំបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## កិច្ចប្រជុំពិភាក្សាអំពីបច្ចុប្បន្នភាពនៃទីផ្សារបរធនបាលកិច្ច ការរៀបចំនិងប្រព្រឹត្តិទៅរបស់បរធនបាលកិច្ច

នាព្រឹកថ្ងៃព្រហស្បតិ៍ ៩ រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែកញ្ញា គ.ស. ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ**) អមដោយសហការី បានជួបប្រជុំពិភាក្សាការងារជាមួយ **ឯកឧត្តម យ៉េត វីណែល** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(**អ.គ.ហ.**) អមដោយសហការី ដើម្បីពិភាក្សាអំពីបច្ចុប្បន្នភាពនៃទីផ្សារបរធនបាលកិច្ច ការរៀបចំនិងប្រព្រឹត្តិទៅរបស់បរធនបាលកិច្ច ព្រមទាំងយន្តការបង្កើត ចុះបញ្ជីបរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច។



រូបភាព៖ កិច្ចប្រជុំពិភាក្សាអំពីបច្ចុប្បន្នភាពនៃទីផ្សារបរធនបាលកិច្ច ការរៀបចំនិងប្រព្រឹត្តិទៅរបស់បរធនបាលកិច្ច។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888